ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ ១៨០/២០

# របាយការណ៍ត្រីមាសទី៣
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងទិសដៅត្រីមាសទី៤ ឆ្នាំ២០២០

## I. ស្ថានភាពទូទៅ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត បានបន្តសកម្មភាព របស់ខ្លួនទៅតាមទិសដៅគ្រោងទុក បើទោះបីជាបាននិងកំពុងតែប្រឈមនឹងសភាពការណ៍វិវត្តថ្មី ដែលមិនអាចប៉ាន់ស្មានបាន ពាក់ព័ន្ធនឹងស្ថានភាពប្រែប្រួលនៃសេដ្ឋកិច្ចពិភពលោក និងបន្ថែមដោយវិបត្តិនៃការរាតត្បាតដោយជំងឺកូវីដ១៩។

ក្រសួង ស្ថាប័ន និងរាជធានី ខេត្ត បានបន្តទិសដៅការងារ ផ្តោតការយកចិត្តទុកដាក់បន្ថែម ទៅលើបញ្ហាវិបត្តិកូវីដ១៩ ដែលជាភាពប្រឈមថ្មី និងដែលជះឥទ្ធិពលដល់ការអនុវត្តសកម្មភាពគ្រប់វិស័យ ធ្វើឱ្យរាំងស្ទះដោយអន្លើ និងត្រូវបន្ថែមភារកិច្ច ក្នុងការដោះស្រាយទប់ស្កាត់ផលប៉ះពាល់ លើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេសអ្នកដែលវិលត្រឡប់ពីប្រទេសក្រៅ ដែលមានចំនួនច្រើនលើសលប់ និងភាគច្រើន ជាអ្នកដែលខ្វះលទ្ធភាព ក្នុងការទ្រទ្រង់ជីវភាព ហើយងាយរងគ្រោះ។ ការជួយសង្គ្រោះពលករដែលវិលត្រឡប់មកពីក្រៅប្រទេស គឺជាកិច្ចការចាំបាច់ ដើម្បីបង្ការទប់ស្កាត់ ការនាំចូលជំងឺកូវីដ១៩ ទៅក្នុងសហគមន៍ និងការដោះស្រាយភាពប្រឈមក្នុងពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ ព្រមទាំងទប់ស្កាត់ការចាញ់បោកមេខ្យល់ ក្នុងការនាំពលករត្រឡប់ទៅប្រទេសគោលដៅវិញ ក្នុងស្ថានភាពដែលមានការរឹតបន្តឹងពីប្រទេសគោលដៅ ដើម្បីការពារជំងឺរាតត្បាត និងវិបត្តិសេដ្ឋកិច្ចដែលកើតមានទូទាំងពិភពលោក ដែលធ្វើឱ្យពលករខាតបង់រឹតតែធ្ងន់ធ្ងរ និងធ្លាក់ទៅក្នុងរលកថ្មីនៃអំពើជួញដូរមនុស្ស។

អាជ្ញាធរ សមត្ថកិច្ច និងលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ និងអង្គការដៃគូ បានធ្វើសកម្មភាពយ៉ាងមមាញឹក ប្រចាំការនៅតាមព្រំដែនទទួលសង្គ្រោះពលករ ដែលវិលត្រឡប់តាមច្រកមិនផ្លូវការ ទាំងយប់ទាំងថ្ងៃ ពិនិត្យកម្តៅ និងផ្តល់សេវាសុខភាព អនុវត្តគោលការណ៍ចត្តាឡីស័កតាមវិធានសុខាភិបាល ផ្តល់អាហារ ត្រៀមមធ្យោបាយដឹកជញ្ជូន ឱ្យបានដល់លំនៅដ្ឋាន និងបន្តតាមដានស្ថានភាពសុខភាព ជីវភាព និងផ្តល់សេវាតាមតម្រូវការផ្សេងៗ និងបន្តតាមដានស្ថានភាព នៅពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ ដែលពួកគាត់រស់នៅ។ លើសពីនេះទៅទៀត វិធានការអប់រំ បង្ការទប់ស្កាត់សកម្មភាពវិលត្រឡប់ទៅប្រទេសថៃវិញ ក្នុងអំឡុងពេលដែលមានការរឹតបន្តឹង ពីប្រទេសគោលដៅក្នុងវិធានការទប់ស្កាត់វិបត្តិកូវីដ១៩ និងដោះស្រាយវិបត្តិសេដ្ឋកិច្ច ការបង្កើនការស៊ើបអង្កេតរកមេខ្យល់ជួញដូរមនុស្ស ក្នុងដំណាក់កាលនេះ ការផ្តល់សេវាជួយជនរងគ្រោះ និងជនងាយរងគ្រោះ ត្រូវបានធ្វើឡើងកាន់តែសកម្ម។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួលពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ អន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារ ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

#### ក.១. ការកសាងច្បាប់

- ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី បានដឹកនាំធ្វើសេចក្តីព្រាងច្បាប់ ស្តីពី"ការពពោះជំនួស"។
- ក្រសួងយុត្តិធម៌ ៖
  - ◦ រដ្ឋសភាបានអនុម័តច្បាប់ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ" (MLA) (ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការណ៍ជាប្រញាប់ ដោយព្រះរាជក្រមលេខ នស/រកម ០៦២០/០២០ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០)។
  - ◦ បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពី "ការប្រឆាំងអំពើរត់ពន្ធមនុស្ស"។

#### ក.២. សន្ធិសញ្ញា

- ក្រសួងយុត្តិធម៌
  - ◦ បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសឡាវ បារាំង និងប្រទេសកូរ៉េខាងត្បូង ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ"
  - ◦ បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសអង់គ្លេស ប៉េរូ និងប្រទេសឡាវ ស្តីពី "ការបញ្ជូនទណ្ឌិត"។

#### ក.៣. គោលនយោបាយ និងអនុស្សរណៈនៃការយោគយល់គ្នា

- ក្រសួងទេសចរណ៍ ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាពជាមួយអង្គការ Friends International។

#### ក.៤. លិខិតបទដ្ឋានគតិយុត្ត

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖ ធ្វើសេចក្តីព្រាងរៀបចំអនុក្រឹត្យ ស្តីពីរបបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។

### ខ. ការបង្ការ ទប់ស្កាត់

#### ខ.១. តាមរយៈការលើកកម្ពស់ការយល់ដឹង

##### ខ.១.១. ការផ្សព្វផ្សាយជាសាធារណៈ

| ល.រ | ផ្សព្វផ្សាយតាមរយៈ | ចំនួនលើក | ចំនួនអ្នកចូលរួម |
|---|---|---|---|
| ១ | វេទិកាសាធារណៈ និងភូមិ-ឃុំមានសុវត្ថិភាព | ៣៣.៨២១ លើក | ១.៤៧៨.៨៥៦ នាក់ |
| ២ | អង្គការដៃគូ | ០៥ លើក | ១៤០ នាក់ |
| សរុប | | ៣៣.៨២៦ លើក | ១.៤៧៨.៩៩៦ នាក់ |

##### ខ.១.២. វេទិកាសាធារណៈ និងភូមិ ឃុំសុវត្ថិភាព

នៅក្នុងខែត្រីមាសទី៣ ឆ្នាំ២០២០នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាក

ស្រុកដោយសុវត្ថិភាព តាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ ការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ មានសុវត្ថិភាព" និងកម្មវិធីផ្សេងៗ ដល់មន្ត្រីរាជការ សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ សាសនិកជន និងប្រជាពលរដ្ឋ សរុបចំនួន ៣៣.៨២១លើក មានអ្នកចូលរួមសរុបចំនួន ១.៤៧៨.៨៥៦នាក់ ធៀបនឹងត្រីមាសទី២ ឆ្នាំ២០២០ មានចំនួន ៨៨៨.២៧៣នាក់ គឺមានការកើនឡើងចំនួន ៥៩០.៥៨៣នាក់) ស្មើនឹង៣៩,៩៣% ក្នុងនោះស្ត្រីចំនួន ៨០៩.៣៤៦នាក់ ដូចមានតារាងលម្អិតខាងក្រោម៖

**តារាងទិន្នន័យការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ និងវេទិកាសាធារណៈ**

| ល.រ | ក្រសួង ស្ថាប័ន | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | រាជធានី-ខេត្ត | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| ក្រសួង ស្ថាប័ន | | | | | | | |
| ១ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ១.៥២៣ | ៦៣.៦៣៩ | ៣៤.៧១៦ | ២០៨ | ៨.៤៩០ | ៤.១១៤ |
| | សរុប ក្រសួង ស្ថាប័ន | ១.៥២៣ លើក | ៦៣.៦៣៩ នាក់ | ៣៤.៧១៦ នាក់ | ២០៨ លើក | ៨.៤៩០ នាក់ | ៤.១១៤ នាក់ |
| រាជធានី-ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | ១.៨៨៤ | ៧៧.០៥២ | ៤៦.៥៥៣ | ៣.១៩៥ | ១៥១.២២១ | ៧៦.៦៧៣ |
| ២ | ខេត្តកណ្តាល | ២.២៨៨ | ៧៦.៧០៧ | ៤១.៨១៤ | ១៦.៨៣ | ៤៥.៦៥០ | ២៥.០៩៨ |
| ៣ | ខេត្តបាត់ដំបង | ១.៨៤៦ | ១៦១.១៨៣ | ៨៦.៥២៧ | ៤៨១ | ១៩.៨៦៩ | ៩.៨៩៩ |
| ៤ | ខេត្តពោធិ៍សាត់ | ១.៥៩៣ | ៦៩.២៤៨ | ៤១.៧១៨ | ៤៥៣ | ១២.២៣០ | ៦៨១៩ |
| ៥ | ខេត្តសៀមរាប | ២.១០២ | ៦០.០៥៩ | ៣៣.០៧០ | ៩៩១ | ២៤.៩៥៣ | ១៣.៩៣០ |
| ៦ | ខេត្តកំពង់ឆ្នាំង | ៣.១៣៦ | ១៦៥.៣៥៩ | ៨៩.២៣០ | ១.៩០៤ | ៦៣.៧២៤ | ៣៣.៦២៦ |
| ៧ | ខេត្តកំពង់ចាម | ៤៥ | ១.៥៨៩ | ៨២៧ | | | |
| ៨ | ខេត្តព្រះសីហនុ | ៤៨០ | ៥៥.៨៦៤ | ៣៤.៨២១ | ៥៤២ | ២៥.៣៣៩ | ១៥.៤០២ |
| ៩ | ខេត្តព្រះវិហារ | ៥៤៩ | ១៩.២២០ | ១០.៣១៥ | ៩៧២ | ៣២.៤១២ | ១៧.៣៥៩ |
| ១០ | ខេត្តស្វាយរៀង | ៣១៣ | ៦.៧៦១ | ២.៤៣២ | ៩៤ | ៣.៣១៩ | ១.២៤៨ |
| ១១ | ខេត្តប៉ៃលិន | ២ | ១៥១ | ១០៦ | ៥៧០ | ១២.១៣៩ | ៦.៩៥១ |
| ១២ | ខេត្តកោះកុង | | | | | | |
| ១៣ | ខេត្តកំពត | | | | | | |
| ១៤ | ខេត្តកំពង់ធំ | ៦៨២ | ២៩.១២៥ | ១៤.៧៣៦ | ២០០ | ៧.១៩២ | ២.៤៥៨ |
| ១៥ | ខេត្តតាកែវ | ១១៩ | ៨.៤០៩ | ៤.៧៨២ | | | |
| ១៦ | ខេត្តក្រចេះ | ៧៧ | ១១.២៧១ | ៥.៦៧៣ | ៦៨ | ៤.១៣៤ | ១.៦៥២ |
| ១៧ | ខេត្តកែប | ១៩៣ | ៨.០៧៧ | ៣.៨៤៥ | ៧០ | ១.៦៥០ | ៧០៣ |
| ១៨ | ខេត្តកំពង់ស្ពឺ | ១៤៥ | ៣.០៣៤ | ៩៧៥ | | | |
| ១៩ | ខេត្តស្ទឹងត្រែង | ២៥៤ | ៨.៣៨៧ | ៤០៦៩ | ៦៩ | ១០៤៧ | ៤៩៣ |
| ២០ | ខេត្តរតនគិរី | | | | | | |
| ២១ | ខេត្តព្រៃវែង | ៣ | ៥.៦១៦ | ៣០៨១ | ៤ | ៦.២៩៤ | ១០.២៨៧ |
| ២២ | ខេត្តត្បូងឃ្មុំ | | | | | | |
| ២៣ | ខេត្តបន្ទាយមានជ័យ | ៤ | ១៦៩ | ១១៨ | | | |
| ២៤ | ខេត្តឧត្តរមានជ័យ | | | | | | |
| ២៥ | ខេត្តមណ្ឌលគិរី | ១.៨៨៤ | ៧៧.០៥២ | ៤៦.៥៥៣ | ៣.១៩៥ | ១៥១.២២១ | ៧៦.៦៧៣ |
| | សរុប រាជធានី-ខេត្ត | ១៧.៥៩៩លើក | ៨៤៤.៣៣៣នាក់ | ៤៧១.២៤៥នាក់ | ១៤.៤៩១លើក | ៥៦២.៣៩៤នាក់ | ៣០០.២៧១នាក់ |

| សរុបរួម ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត | ចំនួន ៣៣.៨២១ លើក | អ្នកចូលរួមសរុប ១.៤៧៨.៨៥៦ នាក់ | ស្ត្រីចំនួន ៨០៩.៣៤៦ នាក់ |
|---|---|---|---|

**ការផ្សព្វផ្សាយអង្គការដៃគូ**

| ឈ្មោះអង្គការ | សកម្មភាព | លើក | មនុស្ស | ស្ត្រី |
|---|---|---|---|---|
| ខេត្តសៀមរាប (អង្គការ វីវើល/ជីវីស៊ី) | ផ្សព្វផ្សាយច្បាប់ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព សិទ្ធិទទួលបានការងារធ្វើ និងទប់ស្កាត់អំពើជួញដូរមនុស្ស។ | ០៥ | ១៤០ | ១១៤ |

### ខ.១.៣. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និង ប្រព័ន្ធអេឡិកត្រូនិក

- **ខេត្តសៀមរាប៖** មន្ទីរព័ត៌មានខេត្ត បានធ្វើការផ្សព្វផ្សាយអប់រំ នៅក្នុងកម្មវិធីវិទ្យុ FM ជាតិនគរភ្នំ ១០៣MHz និងទូរទស្សន៍ជាតិខេត្ត ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការជួញដូរមនុស្ស ចំនួន ១០៤លើក (ផ្សាយផ្ទាល់ ២៧លើក និងចាក់ផ្សាយឡើងវិញ **៧៧**លើក)។
- **ខេត្តតាកែវ៖** មន្ទីរព័ត៌មានខេត្ត បានផ្សព្វផ្សាយច្បាប់នានាពាក់ព័ន្ធ នឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈវិទ្យុគោកធ្លក សរុបចំនួន ៣០អត្ថបទ និង ៣៨លើក។
- **ខេត្តមណ្ឌលគិរី៖** មន្ទីរធម្មការ និងសាសនាខេត្ត បានផ្សព្វផ្សាយតាមរយៈវិទ្យុជាតិ FM 97MHz ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ក្នុងកម្មវិធី "ព្រះពុទ្ធសាសនា ផ្សាភ្ជាប់សង្គម" ចំនួន ២០លើក។
- **ខេត្តកំពង់ចាម៖** មន្ទីរព័ត៌មានខេត្ត បានធ្វើការផ្សព្វផ្សាយតាមរយៈវិទ្យុ និងហ្វេសប៊ុក ស្តីពីការផ្តល់សេវាគាំទ្រដល់ពលករក្នុងកំឡុងពេលកូវីដ១៩ ចំនួន ០២លើក។

### ខ.១.៤. ការចូលរួមជាវាគ្មិន ក្នុងកម្មវិធីនានា

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖
- លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានគណៈកម្មាធិការលើកកម្ពស់តម្លៃសីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ គ.ជ.ស.ស.ខ បានចូលរួមជាវាគ្មិនក្នុងវេទិកាពិភាក្សា ដើម្បីរួមចំណែកធ្វើឱ្យប្រសើរឡើងនូវសីលធម៌សង្គម តម្លៃស្ត្រីនិងគ្រួសារខ្មែរ រៀបចំដោយលេខាធិការដ្ឋាន គ.ជ.ស.ស.ខ នៅអគ្គនាយកដ្ឋានទូរទស្សជាតិកម្ពុជា ចំនួន ០១លើក។
- **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**
- លោកជំទាវវេជ្ជបណ្ឌិត ឧត្តមសេនីយ៍ឯក **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ បានអញ្ជើញចូលរួមធ្វើជាវាគ្មិនផ្សាយបន្តផ្ទាល់ របស់វិទ្យុស្ត្រី FM103.5 MHz រាជធានីភ្នំពេញ លើកិច្ចពិភាក្សាស្តីពី ការកំណត់ អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន ០១លើក។
- ឯកឧត្តម **យឹម វិរៈ** អគ្គលេខាធិការរង ទទួលបន្ទុកក្រុមជំនួយកិច្ចការយុត្តិធម៌ បានចូលរួមប្រជុំក្នុងកម្មវិធីជួបជុំវាគ្មិនផ្នែកបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ដើម្បីជានាការលើកកម្ពស់សិទ្ធិកុមារ និងការអភិវឌ្ឍន៍ ជាមួយលោកប្រធានក្រុមការងារកិច្ចការបង្ការ ទប់ស្កាត់ សម្រាប់ថតចាក់ផ្សាយតាមទូរទស្សន៍ ទ.ទ.ក នៅសាលប្រជុំ ទីស្តីការក្រសួងអប់រំ យុវជន និងកីឡា។
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖

បានចូលរួមជាវាគ្មិនក្នុងកម្មវិធីវិទ្យុសម្លេងស្ត្រីកម្ពុជា ក្រោមប្រធានបទ ការកេងប្រវ័ញ្ចលើកុមារ និងសេវាថែទាំជនរងគ្រោះ ចំនួន០១លើក។

- **ខេត្តបាត់ដំបង៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចូលរួមជាវាគ្មិន

○ ក្នុងកម្មវិធីផ្សព្វផ្សាយរបស់វិទ្យុ FM 91MHz ស្តីពី នៅក៏មានសុវត្ថិភាព ចំណាកស្រុកក៏មានសុវត្ថិភាព ចំនួន ០១លើក។

○ ក្នុងវេទិកា ផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ឱកាសស្វែងរកការងាររបស់ប្រជាពលរដ្ឋ និងវិធានការទប់ស្កាត់ការីករាលដាលជំងឺកូវីដ១៩ ចំនួន ០១លើក។

○ ក្នុងវគ្គសិក្ខាសាលា ស្តីពីការលើកឡើងវិញអំពីការថែទាំជំនួស សិទ្ធិកុមារ កិច្ចការពារកុមារ និងការចូលរួមរបស់កុមារក្នុងការការពាររបស់ពួកគេ ការជួញដូរមនុស្ស ទេសន្តរប្រវេសន៍ និងការផ្សព្វផ្សាយអំពីវគ្គបណ្តុះបណ្តាលផ្សេងៗ ចំនួន ០១លើក។

○ កិច្ចប្រជុំវេទិកាតុមូលជុំទី៦ លើប្រធានបទ "បញ្ហាប្រឈមក្នុងការធ្វើចំណាកស្រុករបស់អនីតិជន និងអំពើជួញដូរមនុស្ស" ចំនួន ០១លើក។

- **ខេត្តកំពង់ចាម** បានចូលរួមផ្សព្វផ្សាយតាមរយៈវិទ្យុជាតិនៃមន្ទីរព័ត៌មានខេត្ត និងតាមបណ្តាញសង្គមហ្វេសប៊ុក ស្តីពីការបញ្ជ្រាបចំណេះដឹងនៃអំពីជំងឺកូវីដ ១៩ ចំនួន ០១លើក។
- **ខេត្តក្រចេះ** បានចូលរួមជាវាគ្មិនក្នុងកម្មវិធីបញ្ឈប់អំពើហិង្សាលើស្ត្រី និងកុមារ ក្រោមប្រធានបទ អំពើហឹង្សា និងការរំលោភសេពសន្ថវៈលើស្ត្រី និងកុមារ តាមរយៈការផ្សាយសម្លេង និងការឡាយតាមបណ្តាញសង្គមហ្វេសប៊ុករបស់វិទ្យុសម្លេងស្ត្រីខេត្តចំនួន ០១លើក។

## ខ.២. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

### ខ.២.១. ការធ្វើអធិការកិច្ច និងពង្រឹងប្រសិទ្ធភាពលើការអនុវត្តការងារ

- **ខេត្តប៉ៃលិន៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះធ្វើអធិការកិច្ចការងារ នៅតាមគ្រឹះស្ថានដែលមានការប្រើប្រាស់កម្លាំងពលកម្មដូចជា សៃឡ កាស៊ីណូ ឡូតដ្ឋ និងអាហារដ្ឋាន ចំនួន ៨០កន្លែង ដោយរកពុំឃើញមានការកេងប្រវ័ញ្ច និងអំពើជួញដូរកម្លាំងពលកម្មទេ។
- **ខេត្តរតនគិរី៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ចុះធ្វើអធិការកិច្ចសាមញ្ញ ១១លើក និងចុះធ្វើអធិការកិច្ចពិសេស១១លើក មិនឃើញមានករណីកេងប្រវ័ញ្ចកម្លាំងពលកម្មឡើយ។

### ខ.២.២. ការគ្រប់គ្រងស្ថិតិ៖ បច្ចុប្បន្នភាពចំណាកស្រុក

- **អគ្គស្នងការដ្ឋាននគរបាលជាតិ**
- ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានធ្វើបច្ចុប្បន្នភាពទិន្នន័យ ចំពោះពលករចំណាកស្រុកទៅក្រៅប្រទេស ប្រចាំខែនីមួយៗ បានពិនិត្យឃើញថានៅតែបន្តមានជាប្រក្រតី ដាក់ស្តែងដូចមានតារាងស្ថិតិខាងក្រោម៖

| ល.រ | បរិយាយ | ចំនួនមនុស្ស | ចំនួនស្ត្រី | អនីតិជន |
|---|---|---|---|---|
| ១ | ខែកក្កដា | ៩១.០៦៥ នាក់ | ៣៩.៣៨៤ នាក់ | ២.០២៧ នាក់ |
| ២ | ខែសីហា | ៩៣.៧០៨ នាក់ | ៤០.៦៣៥ នាក់ | ២.១៤០ នាក់ |
| ៣ | ខែកញ្ញា | ៩៦.៤៩៤ នាក់ | ៤១.៨៩៥ នាក់ | ២.២៥៣ នាក់ |

- **ស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ** បានធ្វើការងារបង្ការ ទប់ស្កាត់ពលរដ្ឋខ្មែរដែលធ្វើចំណាកស្រុកទៅប្រទេសថៃដោយខុសច្បាប់ ចំនួន ០៦លើក មនុស្សចំនួន ២០១នាក់ (ស្រី ៨៦នាក់)

និងបានធ្វើការអប់រំណែនាំ មិនឱ្យធ្វើចំណាកស្រុកដោយខុសច្បាប់ អំពីបញ្ហាជំងឺកូវីដ១៩ បញ្ជូនទៅធ្វើចត្តាឡីស័ក និងពិនិត្យសុខភាព។

- **ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង៖** កម្លាំងល្បាតតាមខ្សែបន្ទាត់ព្រំដែន របស់វរនគរបាលការពារព្រំដែនគោកវរសេនាតូចលេខ ៨១៧ ៨១៩ ៨២៣ និង៣១០ បានចេញល្បាតតាមបន្ទាត់ព្រំដែនភូមិសាស្ត្ររបស់ខ្លួនបានចំនួន ១៨៧លើក ហើយបានប្រទះឃើញពលករឆ្លងដែនខុសច្បាប់ចំនួន ១.៤៥០នាក់ (ស្រី ៦២៩នាក់ អនីតិជន ១១០នាក់) បានធ្វើការអប់រំ និងឱ្យត្រឡប់ទៅផ្ទះវិញ។
- **ស្នងការដ្ឋាននគរបាលខេត្តរតនគិរី៖** កម្លាំងល្បាតតាមខ្សែបន្ទាត់ព្រំដែន របស់វរនគរបាលការពារព្រំដែនគោក បានចេញល្បាតតាមបន្ទាត់ព្រំដែនភូមិសាស្ត្ររបស់ខ្លួន ចំនួន ១៤២លើក (ព្រំដែនកម្ពុជាវៀតណាម ១២៧លើក និងព្រំដែនកម្ពុជា-ឡាវ ១៥លើក) ពុំបានឃើញការលួចឆ្លងដែនខុសច្បាប់ទេ។

**ខ.២.៣. វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ**

- អគ្គស្នងការដ្ឋាននគរបាលជាតិ

- ស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង តាកែវ ក្រចេះ ព្រៃវែង រតនគិរី និងខេត្តព្រះវិហារ បានល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ បានចំនួន ៤២លើក។
- ស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង ក្រចេះ តាកែវ កំពង់ចាម ព្រៃវែង កែប កំពង់ឆ្នាំង កំពង់ស្ពឺ និងខេត្តមណ្ឌលគិរី បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ចារកម្ម និងផ្សព្វផ្សាយ ច្បាប់ប្រឆាំងការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម ភោជនីយដ្ឋាន ផ្ទះសំណាក់ សណ្ឋាគារ ម៉ាស្សា មានដូចតារាងលម្អិតខាងក្រោម៖

| បរិយាយ | ខែកក្កដា | ខែសីហា | ខែកញ្ញា |
|---|---|---|---|
| ចំនួនគោលដៅ | ១៨៣ គោលដៅ | ៣៨៤ គោលដៅ | ៤៧០ គោលដៅ |
| ចំនួនមនុស្ស | ៣.០១៩ នាក់ | ១.១២២ នាក់ | ១.៩០៧ នាក់ |
| ចំនួនស្ត្រី | ១.៧៧១ នាក់ | ៨៣៨ នាក់ | ១.០២២ នាក់ |

**ខ.២.៤. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស**

- ក្រសួងមហាផ្ទៃ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) បានធ្វើសម្ភាសន៍ពលរដ្ឋខ្មែរ និងជនបរទេសដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ចំនួន ១០៤គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ និងបានសាកសួរសុខទុក្ខនារីខ្មែរ ដែលរៀបការរួចហើយទៅរស់នៅសាធារណរដ្ឋកូរ៉េ និងប្រទេសចិន ដោយបានទំនាក់ទំនងតាមទូរស័ព្ទផ្ទាល់របស់សាមីខ្លួនបានចំនួន ១៥នាក់(រស់នៅជាមួយគ្រួសារសុខសប្បាយជាធម្មតា)។

## ខ.៣. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ

- ខេត្តព្រះសីហនុ៖ បន្តសហការជាមួយអង្គការម្លប់តាប៉ាង ធ្វើការទំនាក់ទំនងជាប្រចាំជាមួយបណ្តាញដែលបានដាក់ចំនួន ១.២២៧នាក់ (ម៉ូតូឌុប ក្រុមម៉ូតូកង់បី ផ្ទះសំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្រ ភ្នាក់ងារទេសចរណ៍ និងសហគមន៍) ដើម្បីទប់ស្កាត់ទេសចរណ៍ផ្លូវភេទលើកុមារ។
- ខេត្តស្វាយរៀង៖ បានចុះស្រង់ទិន្នន័យតាមគោលដៅសិប្បកម្ម រោងចក្រ សហគ្រាសដែលសង្ស័យអាចមានការពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ ចំនួន ០១លើក ស្មើនឹង ០៤គោលដៅ

មានកម្មករសរុប ១.៨៥៥នាក់ ស្រី ១.៤៥៤នាក់ ជនបរទេស ចំនួន ២៧នាក់ ជាលទ្ធផលពុំមានការប្រើប្រាស់កម្លាំងពលកម្មកុមារទេ។

- ខេត្តសៀមរាបៈ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះធ្វើអធិការកិច្ចស្រង់ស្ថិតិកុមារ និងកម្មករដែលកំពុងស្នាក់នៅតាមបណ្តាសិប្បកម្មលិតឥដ្ឋ និងបានផ្សព្វផ្សាយបន្ថែមអំពីការទប់ស្កាត់ការប្រើប្រាស់កម្លាំងពលកម្មកុមារក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ នៅស្រុកជីក្រែង បន្ទាយស្រី អង្គរធំ សូទ្រនិគម និងស្រុកក្រឡាញ់ ចំនួន ០៦លើក។

## ខ.៤. ការកាត់បន្ថយភាពងាយរងគ្រោះ តាមរយៈការផ្តល់ប័ណ្ណព្រំដែនដល់មុខសញ្ញាងាយរងគ្រោះ

- រដ្ឋបាលខេត្តចំនួន០៣ គឺខេត្តបន្ទាយមានជ័យ បាត់ដំបង និងខេត្តប៉ៃលិន ដែលមានច្រកប៉ុស្តិ៍អន្តរជាតិនៅតាមព្រំដែន បានផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ (Border Pass) សរុបចំនួន ១.២៣៩ប័ណ្ណ ដល់ពលរដ្ឋខ្មែរដែលរស់នៅក្នុងខេត្តជាប់ព្រំដែន មានៈ
  - ខេត្តបាត់ដំបង ចំនួន ៨៧៤ ប័ណ្ណ
  - ខេត្តបន្ទាយមានជ័យ ចំនួន ១៦២ ប័ណ្ណ
  - ខេត្តប៉ៃលិន ចំនួន ២០៣ ប័ណ្ណ។

# គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

## គ.១. ការងារអនុវត្តច្បាប់

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះទទួលបានពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត។

### គ.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

អគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តច្បាប់) កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបចំនួន ៤០ករណី (ធៀបនឹងត្រីមាសទី២ ឆ្នាំ២០២០ មានចំនួន ៤៩ករណី ថយចុះ ០៩ករណី) ស្មើនឹង ១៨,៣៦%។

ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន ៥០នាក់ (ស្រី ០៨នាក់ អនីតិជន ០២នាក់) និងជនបរទេស ០៦នាក់ មានសញ្ជាតិ (ចិន ០៤នាក់ រុស្ស៊ី ០១នាក់ និងបង់ក្លាដេស ០១នាក់)។

សង្គ្រោះជនរងគ្រោះ ចំនួន ១៥៩នាក់ មានៈ អាយុក្រោម១៥ឆ្នាំ ៣៧នាក់ អាយុ១៥-១៧ឆ្នាំ ០៧នាក់ និងអាយុពី១៨ឆ្នាំឡើង ១១៥នាក់ (ប្រគល់ឱ្យមន្ទីរសង្គមកិច្ច ២៥នាក់ និងប្រគល់ឱ្យគ្រួសារ ១៣៤នាក់) ក្នុងនោះមានបែកជាៈ

*តារាងបូកសរុបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ*

| ល.រ | បរិយាយ | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|---|
| ១ | កក្កដា | ១៥ ករណី | ៦៩ នាក់ | ១៨ នាក់ | |
| ២ | សីហា | ១៣ ករណី | ៧០ នាក់ | ១៩ នាក់ | ចិន៤ រុស្ស៊ី១ បង់ក្លាដេស១ |
| ៣ | កញ្ញា | ១២ ករណី | ២០ នាក់ | ១៣ នាក់ | |
| សរុបត្រីមាសទី៣ | | ៤០ ករណី | ១៥៩ នាក់ | ៥០ នាក់ | ០៦ នាក់ |

១. ករណីអំពើជួញដូរមនុស្ស

បង្ក្រាបបាន ១០ករណី លើ២១ករណី (ថយចុះ ១១ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ១៤នាក់ (ស្រី ០៤នាក់)។ សង្គ្រោះជនរងគ្រោះចំនួន ៩៨នាក់ មានៈ អាយុក្រោម១៥ឆ្នាំ ១១នាក់ និងអាយុ១៨ឆ្នាំឡើង ៨៧នាក់ (ប្រគល់ឱ្យមន្ទីរសង្គមកិច្ច ០៩នាក់ និងប្រគល់ឱ្យគ្រួសារ ៨៩នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|
| -ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | ០៤ | ៣១ | ០៤ | |
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ០៣ | ៤០ | ០៥ | |
| -ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច | ០១ | ១៦ | ០២ | |
| -ការទទួលមនុស្សដោយមានគោលដៅជួយដល់ជនល្មើស | ០១ | ១០ | ០២ | បង់ក្លាដេស១ |
| -ការទិញពេស្យាចារកុមារ | ០១ | ០១ | ០១ | |
| *សរុប* | *១០ ករណី* | *៩៨ នាក់* | *១៤ នាក់* | *០១ នាក់* |

២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន ៣០ករណី លើ២៨ករណី (កើនឡើង ០២ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ៣៦នាក់ (ស្រី ០១នាក់) ជនសង្ស័យជាអនីតិជន ០២នាក់។ សង្គ្រោះជនរងគ្រោះចំនួន ៦១នាក់ មានៈ អាយុក្រោម១៥ឆ្នាំ ២៦នាក់ អាយុ១៥-១៧ឆ្នាំ ០៧នាក់ និងអាយុ១៨ឆ្នាំឡើង ២៨នាក់ (ប្រគល់ឱ្យមន្ទីរសង្គមកិច្ច ១៦នាក់ និងប្រគល់ឱ្យគ្រួសារ ៤៥នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|
| -សញ្ចារកម្ម | ០៣ | ១៩ | ០៧ | ចិន៤ រុស្ស៊ី១ |
| -សញ្ចារកម្ម(មានអនីតិជន) | ០១ | ០៤ | ០១ | |
| -ស្ថានទម្ងន់ទោសនៃសញ្ចារកម្ម | ០២ | ០៨ | ០៣ | |
| -បទល្មើសទាក់ទងនឹងពេស្យាចារកុមារ | ០១ | ០៦ | ០២ | |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ១៧ | ១៧ | ១៧(អនី.២) | |
| -អំពើអាសប្រឋាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៦ | ០៧ | ០៦ | |
| *សរុប* | *៣០ ករណី* | *៦១ នាក់* | *៣៦ នាក់(អនី.២)* | *០៥ នាក់* |

**គ.២. កិច្ចការយុត្តិធម៌**

ទិន្នន័យទទួលបានពីក្រុមការងារកិច្ចការយុត្តិធម៌ ដឹកនាំដោយក្រសួងយុត្តិធម៌ ដែលបានដកស្រង់ពីសាលាដំបូងរាជធានី-ខេត្ត បានធ្វើចំណាត់ការលើសំណុំរឿងបទល្មើសក្រោមច្បាប់ ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ មាត្រាពាក់ព័ន្ធនៃក្រមព្រហ្មទណ្ឌ ជាលទ្ធផលតាមដំណាក់កាលនៃនីតិវិធីតុលាការ មានដូចខាងក្រោម៖

គ.២.១. ចំណាត់ការរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត

ចំណាត់ការរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត សរុបមានចំនួន ៧២ករណី ជនរងគ្រោះចំនួន ១០១នាក់ (ស្រី ៨១នាក់) អនីតិជន ៤៩នាក់ (ស្រី ៣៩នាក់) ជនត្រូវចោទមានចំនួន ៨១នាក់ (ស្រី ១២នាក់) ហើយបានចំណាត់ការដោយបានបញ្ជូនទៅស៊ើបសួរចំនួន ៣៣ករណី តម្កល់ទុកឥតចាត់ការគ្មាន និងកំពុងចាត់ការចំនួន ៣៩ករណី ដូចមានតារាងលម្អិតខាងក្រោម៖

*<u>តារាងចំណាត់ការរឿងក្តីជួញដូរមនុស្សរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត៖</u>*

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនល្មើស | | | | ប្រភេទចំណាត់ការ | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | បញ្ជូនទៅស៊ើបសួរ | តម្កល់ទុកឥតចាត់ការ | កំពុងចាត់ការ |
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | | |
| សរុប | ១០ | ៤២ | ០៧ | ៣៩ | ៦៩ | ១២ | ០ | ០ | ៣៣ | ០ | ៣៩ |
| ៧២ | ៥២ នាក់ | | ៤៩ នាក់ | | ៨១ នាក់ | | ០ | | ៧២ ករណី | | |

**គ.២.២. ចំណាត់ការរបស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានី-ខេត្ត**

ចំណាត់ការរបស់ចៅក្រមស៊ើបសួររាជធានី-ខេត្ត សរុបមានចំនួន ៦០ករណី ជនរងគ្រោះចំនួន ៩២នាក់ (ស្រី ៨៤នាក់) អនីតិជន ៤៩នាក់(ស្រី ៤៦នាក់) ជនត្រូវចោទមានចំនួន ៧៤នាក់ នៅក្នុងឃុំចំនួន ៦៣នាក់ (ស្រី ០២នាក់) នៅក្រៅឃុំចំនួន ១១នាក់ (ស្រី ០២នាក់) និងបានចំណាត់ការបញ្ជូនទៅជម្រះចំនួន ៤១ករណី លើកលែងចោទគ្មាន និងកំពុងចាត់ការចំនួន ១៩ករណី ដូចមានតារាងលម្អិតខាងក្រោម៖

*<u>តារាងចំណាត់ការរឿងក្តីជួញដូរមនុស្សរបស់ចៅក្រមស៊ើបសួររាជធានី-ខេត្ត៖</u>*

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនត្រូវចោទ | | | | នៅក្នុងឃុំ | | | | នៅក្រៅឃុំ | | | | ប្រភេទចំណាត់ការ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | ជូនទៅជម្រះ | លើកលែង | កំពុងចាត់ការ |
| | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ៤១ | ០ | ១៩ |
| សរុប | ០៥ | ៣៨ | ០៣ | ៤៦ | ៦១ | ០៤ | ០៩ | ០ | ៦១ | ០២ | ០ | ០ | ០ | ០២ | ០៩ | ០ | | | |
| ៦០ | ៤៣ នាក់ | | ៤៩ នាក់ | | ៦៥ នាក់ | | ០៩ នាក់ | | ៦៣ នាក់ | | | | ១១ នាក់ | | | | ៦០ ករណី | | |

**គ.២.៣. ចំណាត់ការរបស់ចៅក្រមជំនុំជម្រះ នៃសាលាដំបូងរាជធានី-ខេត្ត**

ចំណាត់ការរបស់ចៅក្រមជំនុំជម្រះរាជធានី-ខេត្ត សរុបមានចំនួន ៥១ករណី ជនរងគ្រោះចំនួន ៧៣នាក់ (ស្រី ៦៩នាក់) អនីតិជន ៣៩នាក់(ស្រី ៣៨នាក់) ជនជាប់ចោទសរុប ៦១នាក់(ស្រី ១៤នាក់) និងប្រភេទចំណាត់ការ(ទោសព្យួរគ្មាន ពិន័យជាប្រាក់គ្មាន រួចផុតពីបទចោទគ្មាន រំលត់បណ្តឹងអាជ្ញាគ្មាន ចាត់ការរួច ៣៤ករណី ផ្តន្ទាទោសដាក់ពន្ធនាគារក្នុងឃុំ ៤៩នាក់ នៅក្រៅឃុំគ្មាន និងកំពង់ចាត់ការ ១៧ករណី) ដូចមានតារាងលម្អិតខាងក្រោម៖

*<u>តារាងចំណាត់ការរឿងក្តីជួញដូរមនុស្សរបស់ចៅក្រមជំនុំជម្រះរាជធានី-ខេត្ត៖</u>*

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនជាប់ចោទ | | ប្រភេទចំណាត់ការ | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | | | ទោសព្យួរ | ពិន័យជាប្រាក់ | រួចផុតពីបទចោទ | រំលត់បណ្តឹងអាជ្ញា | ចាត់ការរួច | ផ្តន្ទាទោសពន្ធនាគារ | | កំពុងចាត់ការ |
| សរុប | ប | ស | ប | ស | ប | ស | | | | | | ក្នុងឃុំ | ក្រៅឃុំ | |
| ៥១ | ០៣ | ៣១ | ០១ | ៣៨ | ៤៧ | ១៤ | ០ | ០ | ០ | ០ | ៣៤ ករណី | ៤៩ នាក់ | ០ | ១៧ករណី |
| | ៣៤ នាក់ | | ៣៩ នាក់ | | ៦១ នាក់ | | | | | | | | | |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ឃ.១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និង ផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

**ឃ.១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់**

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖

- បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលបានធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានា តាមច្រកព្រលានយន្តហោះអន្តរជាតិភ្នំពេញ និងច្រកព្រំដែនអន្តរជាតិបាវិត សរុបចំនួន ៧៦នាក់ (ស្ត្រី ៧២នាក់) កុមារី ០១នាក់ មកពីៈប្រទេសចិន ៧០នាក់ វៀតណាម(ឆ្លងពីចិន)០១នាក់ និងប្រទេសម៉ាឡេស៊ី ០៥នាក់ ក្នុងនោះ ករណីអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ ៥៨នាក់ និងងាយរងគ្រោះ ១១នាក់ និងជួញដូរពលកម្ម ០៧នាក់។

- មណ្ឌលសំចតប៉ោយប៉ែត បានទទួលជនងាយរងគ្រោះនិរទេសពីប្រទេសថៃចំនួន ២៣.៨៤៥នាក់ (ស្ត្រី ៩.៩១៤នាក់) កុមារ ២.៥៤៣នាក់ (កុមារី ១.២៤០នាក់) តាមច្រកអន្តរជាតិប៉ោយប៉ែត និងច្រកអូរបីជាន់។

*ដោយឡែក* ក្រុមការងារមជ្ឈមណ្ឌលសំចត បានធ្វើការសម្ភាសដើម្បីកំណត់អត្តសញ្ញាណរកមុខសញ្ញាជនរងគ្រោះ និងងាយរងគ្រោះចំនួន ១៩នាក់ (ស្ត្រី ០៤នាក់) កុមារ ២៤នាក់ (កុមារី ០៧នាក់) ជាករណីងាយរងគ្រោះ។

- **ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត**

**ស្នងការដ្ឋាននគរបាលខេត្ត ចំនួន០៤** បានទទួល និងសម្ភាសពលករខ្មែរ ដែលអាជ្ញាធរបរទេសចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ និងច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-វៀតណាម ចំនួន ១០៤លើក មនុស្សចំនួន ១.២៧៤នាក់(ស្រី ៥១៦នាក់ អនីតិជន ៥១នាក់) ក្នុងនោះមាន៖

| | | | |
|---|---|---|---|
| - ខេត្តបន្ទាយមានជ័យ | ចំនួន ៥៧លើក | មនុស្សចំនួន១.០៩៣នាក់<br>អនីតិជនចំនួន ៤៤នាក់។ | (ស្រី ៤៦៩នាក់) |
| - ខេត្តបាត់ដំបង | ចំនួន ០៩លើក | មនុស្សចំនួន ៥១នាក់ | (ស្រី ១៤នាក់)។ |
| - ខេត្តកោះកុង | ចំនួន ៣៥លើក | មនុស្សចំនួន ១១៧នាក់<br>អនីតិជនចំនួន ០១នាក់។ | (ស្រី ២៥នាក់) |
| - ខេត្តស្វាយរៀង | ចំនួន ០៣លើក | មនុស្សចំនួន ១៣នាក់<br>អនីតិជនចំនួន ០៦នាក់។ | (ស្រី ០៨នាក់) |

### ឃ.២. ការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ) បានបញ្ជូនជនរងគ្រោះដោយអំពើជួញដូមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ការរំលោភបំពានផ្លូវភេទ ទៅទទួលសេវាស្តារនីតិសម្បទា តាមមណ្ឌលអង្គការដៃគូពាក់ព័ន្ធចំនួន ៣២នាក់(ស្ត្រី ១២នាក់) កុមារា ០១នាក់ ជាករណីរំលោភបំពានផ្លូវភេទ ០១នាក់ អាជីវកម្មផ្លូវភេទ ១៤នាក់ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ១៧នាក់។

### ឃ.៣. ការធ្វើសមាហរណកម្មជនរងគ្រោះ និងជនងាយរងគ្រោះ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ) បានសហការជាមួយអាជ្ញាធរមូលដ្ឋាន

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ) បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានធ្វើសមាហរណកម្មជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ រំលោភបំពានផ្លូវភេទត្រឡប់ទៅសហគមន៍វិញ ចំនួន ០៦នាក់(ស្ត្រី០៦នាក់) ជាករណីអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈ ០៥នាក់ ករណីរំលោភសេពសន្ថវៈ ០១នាក់។

### ខ. ការទទួលសាកសពបញ្ជូនត្រឡប់

ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង៖ ពលរដ្ឋខ្មែរដែលបានស្លាប់ដោយសារជំងឺ និងគ្រោះថ្នាក់ផ្សេងៗក្នុងប្រទេសថៃ ហើយត្រូវបានក្រុមគ្រួសារនាំចូលតាមច្រកទ្វារអន្តរជាតិដូង មានចំនួន ១៦នាក់ ស្រី ០៣នាក់។

## III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

#### ក.១. ការងារបណ្តុះបណ្តាល

ក.១.១.ការបណ្តុះបណ្តាលក្នុងប្រទេស

តារាងវគ្គបណ្តុះបណ្តាល

| ល.រ | សកម្មភាព | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមនារី |
|---|---|---|---|---|
| ១ | នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ៖ | | | |
| | -សហការជាមួយអង្គការសកម្មភាពដើម្បីកុមារ (APLE) បើកវគ្គបណ្តុះបណ្តាល ស្តីពីការឆ្លើយតបបទល្មើសផ្លូវភេទកុមារតាមប្រព័ន្ធអ៊ីនធឺណេត ដល់នគរបាលជំនាញ។ | ០១ | ១៦ | ០៦ |
| | -បើកវគ្គបណ្តុះបណ្តាល ស្តីពីការអនុវត្តបែបកុមារមេត្រី ដើម្បីការពារកុមាររងគ្រោះ និងកុមារជាសាក្សី ក្នុងនីតិវិធីស៊ើបអង្កេតបទ ល្មើសកេងប្រវ័ញ្ចផ្លូវភេទ។ | ០១ | ៣០ | ០៥ |
| ២ | ខេត្តសៀមរាប៖ | | | |
| | -លេខាធិការដ្ឋាន សហការជាមួយមន្ទីរអប់រំយុវជន និងកីឡា បើកវគ្គបណ្តុះបណ្តាល ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងរូបភាពនៃអំពើជួញដូរមនុស្ស ដល់លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងក្រុមយុវជន។ | ០១ | ៦១ | ៣៨ |
| | -លេខាធិការដ្ឋាន សហការជាមួយអង្គការវីវលជីវីស៊ី បើកវគ្គបណ្តុះបណ្តាល ស្តីពីគោលការណ៍ណែនាំនូវការដោះស្រាយវិវាទទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្សដើម្បីពង្រឹងសមត្ថភាព អំពីការការពារសិទ្ធិការងាររបស់ពលករចំណាកស្រុក ការកំណត់អត្តសញ្ញាណជនល្មើស និងជនរងគ្រោះជនងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដល់ក្រុមគ្រូបង្គោល ក្រុមប្រឹក្សាឃុំ និងប៉ូលីសប៉ុស្តិ៍។ | ០១ | ២២ | ០៩ |
| | -មន្ទីរអប់រំយុវជន និងកីឡា សហការជាមួយអង្គការមូលនិធិអេ២១ បើកវគ្គបណ្តុះបណ្តាល ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចលើកុមារ ដល់លោកគ្រូ អ្នកគ្រូ។ | ០១ | ៤៥ | ១៦ |
| ៣ | ខេត្តកំពត៖ | | | |
| | -ស្នងការដ្ឋាននគរបាលខេត្ត បានបើកវគ្គបណ្តុះបណ្តាលស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ដល់កម្លាំងនគរបាលក្របខណ្ឌថ្មី និងមន្ត្រីជំនាញ។ | ០១ | ៧៥ | ២២ |
| | -បានសហការជាមួយអង្គការសកម្មភាពដើម្បីកុមារ បើកវគ្គបណ្តុះបណ្តាល ស្តីពីការអនុវត្តបែបកុមារមេត្រី ដើម្បីកុមាររងគ្រោះ និងកុមារជាសាក្សី ក្នុងនីតិវិធីស៊ើបអង្កេតបទល្មើស កេងប្រវ័ញ្ចផ្លូវភេទលើកុមារ ដល់មន្ត្រីនគរបាលជំនាញ។ | ០១ | ២៣ | ០៣ |
| | -បានសហការជាមួយអង្គការសកម្មភាពដើម្បីកុមារ បើកវគ្គបណ្តុះបណ្តាល ស្តីពីការឆ្លើយតបនឹងបទល្មើសផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណេត។ | ០២ | ៣៩ | ១០ |
| ៤ | ខេត្តប៉ៃលិន៖ សហការជាមួយអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ(CWCC) បើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងការទប់ស្កាត់អំពើជួញដូរមនុស្ស។ | ០១ | ៣៣ | ១១ |
| ៥ | ខេត្តព្រះវិហារ៖ ស្នងការដ្ឋាននគរបាលខេត្ត សហការជាមួយអង្គការសម្ព័ន្ធចាប់ដៃ បើកវគ្គបណ្តុះបណ្តាល ស្តីពីនីតិវិធីស៊ើបអង្កេតករណីជួញដូរមនុស្ស និងក្រមសីលធម៌ក្នុងការសម្ភាស កំណត់អត្តសញ្ញាណជនរងគ្រោះ។ | ០១ | ៣០ | ០៩ |
| ៦ | ខេត្តកែប៖ ស្នងការដ្ឋាននគរបាលខេត្ត បានសហការជាមួយអង្គការសកម្មភាពដើម្បីកុមារ បើកវគ្គបណ្តុះបណ្តាល ស្តីពីការឆ្លើយតបនឹងបទល្មើសផ្លូវភេទលើកកុមារ តាមប្រព័ន្ធ Internet។ | ០១ | ២០ | ០៥ |
| ៧ | ខេត្តស្វាយរៀង៖ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានសហការជាមួយក្រុមហ៊ុនសហគ្រាសចំនួន០៨ បើកវគ្គបណ្តុះបណ្តាល ស្តីពីបំនិនជីវិត ច្បាប់ការងារ សុខភាព ការជួយសង្គ្រោះបឋម ច្បាប់ពាក់ព័ន្ធនឹងការជួញដូរមនុស្ស និងគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ។ | ០២ | ២២៨ | ១៤៨ |

| | | | | |
|---|---|---|---|---|
| ៨ | **ខេត្តត្បូងឃ្មុំ៖** ស្នងការដ្ឋាននគរបាលខេត្ត បានសហការជាមួយអង្គការសម្ព័ន្ធចាប់ដៃ បើកវគ្គបណ្តុះបណ្តាល ស្តីពីនីតិវិធីស៊ើបអង្កេតករណីជួញដូរមនុស្ស ក្រមសីលធម៌ក្នុងការសម្ភាសន៍ កំណត់អត្តសញ្ញាណជនរងគ្រោះ។ | ០១ | ៣០ | |
| ៩ | **ខេត្តកំពង់ធំ៖**លេខាធិការដ្ឋាន សហការជាមួយអង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី បើកវគ្គបណ្តុះ បណ្តាលសម្រាប់គ្រូបង្គោល ស្តីពី យុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងវិស័យនេសាទសមុទ្រក្នុងប្រទេសថៃ នៅសាលាខេត្ត។ | ០១ | ២៣ | ១១ |
| ១០ | **ខេត្តកំពង់ចាម៖** លេខាធិការដ្ឋាន បើកវគ្គបណ្តុះបណ្តាលស្តីពី នីតិវិធីដោះស្រាយពាក្យបណ្តឹងពលករ ចំណាកស្រុក ដល់មន្ត្រីលេខាធិការដ្ឋាន ០១វគ្គ និងវគ្គបណ្តុះបណ្តាលស្តីពីនីតិវិធីទៅធ្វើការនៅក្រៅប្រទេស ដល់មន្ត្រី គ.ខ.ប.ជ ថ្នាក់ឃុំ សង្កាត់ ស្រុក ០១វគ្គ។ | ០២ | ៥៤ | ២៤ |
| ១១ | **ខេត្តព្រៃវែង៖** លេខាធិការដ្ឋាន គ.ខ.ប.ជ បានសហការជាមួយអង្គការជំនួយផ្លូវច្បាប់ដល់ស្ត្រី និងកុមារ បើកវគ្គបណ្តុះបណ្តាល ស្តីពីសិទ្ធិរបស់ពលករចំណាកស្រុកទូកនេសាទ និងអំពើជួញដូរមនុស្ស ដល់មន្ត្រីមកពីក្រុមកាងារ គ.ខ.ប.ជ ទាំង៦ និងអង្គការដៃគូ។ | ០១ | ២០ | ១១ |
| | សរុប | ១៩ វគ្គ | ៧៤៩ នាក់ | ៣២៨ នាក់ |

## ក.២. សិក្ខាសាលា

- **ថ្នាក់ជាតិ**
  - គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
    - បានបើកសិក្ខាសាលាថ្នាក់ជាតិលើកទី២ កម្រិតថ្នាក់ដឹកនាំស្តីពី "កតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាពរៀបរយ និងស្របច្បាប់" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃ។
    - សហការជាមួយអង្គការឆាលហ្វាន់ បានរៀបចំសិក្ខាសាលាថ្នាក់ជាតិ "ស្តីពីកិច្ចការការពារកុមារពីការជួញដូរ ការរំលោភបំពានផ្សេងៗ និងការធ្វើទេសន្តរប្រវេសន៍" នៅសណ្ឋាគារកាំបូតឌីយ៉ាណា។
    - សហការជាមួយអង្គការ ASEAN ACT បានរៀបចំសិក្ខាសាលា "ផ្ទៀងផ្ទាត់បញ្ជាក់របកគំហើញ និងអនុសាសន៍ កំណត់ផែនទីភាគីពាក់ព័ន្ធផ្នែកសមាសភាព និងបរិយាប័ន" នៅសណ្ឋាគារកាំបូឌីយ៉ាណា។
  - **ក្រសួងអប់រំ យុវជន និងកីឡា** បានរៀបចំសិក្ខាសាលា ស្តីពីការបង្ការ ទប់ស្កាត់ អំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទកុមារ ក្រោមអធិបតីភាព លោកជំទាវ **សឿ សុជាតា** អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា សិក្ខាកាមចូលរួមសរុប ៣០នាក់ (ស្រី ០៣នាក់) នៅសណ្ឋាគារ ខេមរាអង្គរ ខេត្តសៀមរាប។
  - **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិលើសេចក្តីព្រាងចុងក្រោយនៃគោលការណ៍ណែនាំ ស្តីពីយន្តការបញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្ស មានសមាសភាពចូលរួមសរុបចំនួន ៩៨នាក់(ស្ត្រី ៣៧នាក់) នៅសណ្ឋាគារសាន់វ៉េ។
- **ថ្នាក់ក្រោមជាតិ**
  - **ខេត្តព្រៃវែង** ប្រធានលេខាធិការដ្ឋានខេត្ត គ.ខ.ប.ជខេត្ត និងក្រុមការងារថ្នាក់ស្រុក បានសហការជាមួយអង្គការ Woman ក្រោមការឧបត្ថម្ភរបស់អង្គការ ឆាលហ្វាន់ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងដាក់ឱ្យដំណើរការគម្រោង "សហគមន៍មានសុវត្ថិភាពសម្រាប់កុមារ" នៅស្រុកកំពង់ត្របែក មានអ្នកចូលរួមសរុបចំនួន ៦២នាក់ ស្រី១៨នាក់។

## ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ខ.១ កិច្ចប្រជុំ ជាអន្តរជាតិនៅក្នុងប្រទេស និងក្រៅប្រទេស

➢ កិច្ចប្រជុំក្នុងប្រទេស

• ថ្នាក់ជាតិ

▪ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)

- **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់៖

  - ក្នុងកិច្ចប្រជុំជាន់ខ្ពស់រវាងក្រសួង ស្ថាប័ន ពាក់ព័ន្ធ និងអង្គការសហប្រជាជាតិប្រចាំកម្ពុជា ស្តីពីកម្មវិធីរួមគ្នាដើម្បីគាំទ្រជនទេសន្តរប្រវេសន៍ ដែលវិលត្រឡប់ក្នុងស្ថានភាពវិបត្តិជំងឺកូវីដ១៩ និងផលប៉ះពាល់ នៅទីស្តីការក្រសួងមហាផ្ទៃ។
  - ក្នុងកិច្ចប្រជុំរបាយការណ៍ឆមាសទី១ និងលើកទិសដៅអនុវត្តបន្ត ឆ្នាំ២០២០ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកចូលរួមសរុបចំនួន ៥២នាក់ (ស្រី ១៥នាក់) នៅទីស្តីការក្រសួងមហាផ្ទៃ។

- លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ៖

  - បានដឹកនាំកិច្ចប្រជុំពិភាក្សាស្តីពី ផែនការក្នុងការអនុវត្តកម្មវិធីរួមគ្នា ជួយគាំទ្រដល់ពលករទេសន្តរប្រវេសន៍ ដែលវិលត្រលប់កំឡុងពេលវិបត្តិកូវីដ១៩ និងផលប៉ះពាល់ ថ្នាក់បច្ចេកទេស រវាង តំណាងអង្គការយូអិន តំណាងអង្គការIOM អគ្គលេខាធិការរង ទទួលបន្ទុកការងារទំនាក់ទំនងអន្តរជាតិ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ តំណាងអង្គការ UN IOM WHO UNICEF UNFPA និងអង្គការដៃគូពាក់ព័ន្ធ នៅសាលប្រជុំគ.ជ.ប.ជ។
  - បានដឹកនាំកិច្ចប្រជុំ "ពិនិត្យ និងផ្តល់យោបល់ ទៅលើខ្លឹមសារសេចក្តីព្រាងសៀវភៅ ការអប់រំ និងលំនាំនៃការបង្រៀនស្តីពី ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស" នៅសាលប្រជុំគ.ជ.ប.ជ។
  - បានដឹកនាំកិច្ចប្រជុំពិភាក្សា កែសម្រួលរបាយការណ៍បូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆមាសទី១ ឆ្នាំ២០២០ នៅសាលប្រជុំ គ.ជ.ប.ជ។
  - បានដឹកនាំកិច្ចប្រជុំពិភាក្សា រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការសម្ព័ន្ធចាប់ដៃ ស្តីពីគម្រោងកិច្ចសហប្រតិបត្តិការទប់ស្កាត់ជនរងគ្រោះ និងជនចំណាកស្រុកខុសច្បាប់ ក្នុងដំណាក់កាលជំងឺកូវីដ១៩ អ្នកចូលរួមចំនួន ០៧នាក់ (ស្រី ០២នាក់) នៅសាលប្រជុំ គ.ជ.ប.ជ។
  - បានដឹកនាំកិច្ចប្រជុំពិភាក្សា ជាមួយមន្ទីរពាក់ព័ន្ធនានារបស់រដ្ឋបាលខេត្តបាត់ដំបង ស្តីពីផែនការសកម្មភាពក្នុងការអនុវត្តគម្រោងរួមគ្នា រវាងរាជរដ្ឋាភិបាល និងយូអិន ទៅក្នុងសហគមន៍តាមបណ្តាស្រុករបស់ខេត្តបាត់ដំបង នៅសាលាខេត្តសៀមរាប។
  - បានដឹកនាំកិច្ចប្រជុំពិភាក្សា ជាមួយមន្ទីរពាក់ព័ន្ធនានារបស់រដ្ឋបាលខេត្តបន្ទាយមានជ័យ ស្តីពីផែនការសកម្មភាពក្នុងការអនុវត្តគម្រោងរួមគ្នា រវាងរាជរដ្ឋាភិបាល និងយូអិន ទៅក្នុងសហគមន៍តាមបណ្តាស្រុករបស់ខេត្តបន្ទាយមានជ័យ នៅសណ្ឋាគារសោម៉ាទេវី ខេត្តសៀមរាប។
  - បានដឹកនាំកិច្ចប្រជុំពិភាក្សា ជាមួយមន្ទីរពាក់ព័ន្ធនានារបស់រដ្ឋបាលខេត្តសៀមរាប ស្តីពីផែនការសកម្មភាពក្នុងការអនុវត្តគម្រោងរួមគ្នា រវាងរាជរដ្ឋាភិបាល និងយូអិន ទៅក្នុងសហគមន៍ តាមបណ្តាស្រុករបស់ខេត្តសៀមរាប នៅសាលាខេត្តសៀមរាប។
  - បានដឹកនាំកិច្ចប្រជុំឆមាសទី១ ឆ្នាំ២០២០ ដើម្បីពិនិត្យ អំពីការប្រឈម លទ្ធផល និងទិសដៅអនុវត្តបន្ត ក្នុងក្របខ័ណ្ឌកិច្ចសហការ លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាមួយអង្គការ

ដៃគូពាក់ព័ន្ធ អំឡុងពេលវិបត្តិជំងឺកូវីដ-១៩ អ្នកចូលរួមសរុប ៣២នាក់ (ស្រី ០៩នាក់) នៅសាលប្រជុំគ.ជ.ប.ជ។

- លោកជំទាវ ឧត្តមសេនីយ៍ឯក **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ៖
  - ○ បានដឹកនាំកិច្ចប្រជុំស្តីពី សកម្មភាពពិនិត្យកែសម្រួលផែនការសកម្មភាពឆ្នាំ២០២០ របស់ក្រុមជំនួយកិច្ចការទាំង៦ និងលេខាធិការដ្ឋានរដ្ឋបាល សរុប នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដើម្បីដាក់បញ្ចូលក្នុងទម្រង់គំរូផែនការសកម្មភាព របស់អគ្គនាយកដ្ឋាន និងអង្គភាពប្រហាក់ប្រហែលចំណុះក្រសួងមហាផ្ទៃឱ្យមានការឯកភាពតែមួយ។ មានអ្នកចូលរួមចំនួន ១១នាក់ (ស្រី ០៣នាក់) នៅសាលប្រជុំគ.ជ.ប.ជ។
  - ○ បានដឹកនាំកិច្ចប្រជុំស្តីពី "ការពិនិត្យ និងផ្តល់យោបល់ទៅលើខ្លឹមសារ សេចក្តីព្រាងសៀវភៅការអប់រំ និងលំនាំនៃការបង្រៀនស្តីពី ការទប់ស្កាត់អំពើជួញដូរមនុស្ស" មានអ្នកចូលរួមចំនួន ១៦នាក់ (ស្រី ០១នាក់) នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
  - ○ បានដឹកនាំកិច្ចប្រជុំពិភាក្សាសម្រេចរវាង គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការឆាលហ្វាន់ ដើម្បីរៀបចំសិក្ខាសាលាថ្នាក់ជាតិ ស្តីពីកិច្ចការពារកុមារពីអំពើជួញដូរការរំលោភបំពានផ្សេងៗ និងការធ្វើទេសន្តរប្រវេសន៍ អ្នកចូលរួមចំនួន ០៩នាក់(ស្ត្រី ០៣នាក់) នៅសាលប្រជុំគ.ជ.ប.ជ។
  - ○ បានដឹកនាំកិច្ចប្រជុំពិនិត្យ និងដកស្រង់របាយការណ៍ ដើម្បីផ្ញើជូនតាមការស្នើសុំ របស់ក្រុមការងារក្រសួងមហាផ្ទៃ ទទួលការងារប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនក្នុងក្របខណ្ឌអាស៊ាន អ្នកចូលរួមចំនួន ១៥នាក់(ស្រី ០២នាក់) នៅសាលប្រជុំគ.ជ.ប.ជ។

- ▪ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖** សហការជាមួយអង្គការបេសកកម្មអន្តរជាតិ (IJM) រៀបចំកិច្ចប្រជុំវាយតម្លៃលើការបណ្តុះបណ្តាលស្តីពី គោនយោបាយ និងបទដ្ឋានអប្បបរមាស្តីពី កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងបទដ្ឋានពាក់ព័ន្ធមួយចំនួនទៀត ដែលបានបណ្តុះបណ្តាលរួចនៅខេត្តក្រចេះ និងកំពង់ធំ ចំនួន ០១លើក។

- **ថ្នាក់ក្រោមជាតិ**
  - ▪ **ខេត្តសៀមរាប៖** លេខាធិការដ្ឋានគ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំយុត្តិធម៌ព្រហ្មទណ្ឌស្តីពី ការនាំចេញដោយមិនស្របច្បាប់ នីតិវិធីនៃការឃាត់ខ្លួន ឃុំខ្លួនអនីតិជន ចំនួន ០១លើក នៅសាលាខេត្ត មានអ្នកចូលរួម ៨៧នាក់ ស្រី២៦នាក់។
  - ▪ **ខេត្តកំពង់ចាម៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយអង្គការពលកម្មអន្តរជាតិ ILO រៀបចំកិច្ចប្រជុំផ្សព្វផ្សាយស្តីពី លទ្ធផលនៃការស្រាវជ្រាវផលប៉ះពាល់លើពលករទេសន្តរប្រវេសន៍ដោយជំងឺកូវីដ១៩ និងក្រមសីលធម៌ក្នុងការជ្រើសរើស ព្រមទាំងយន្តការដោះស្រាយបណ្តឹង របស់ពលករ ចំនួន ០១លើក មានអ្នកចូលរួម ៤៦នាក់ ស្រី២៣នាក់។
  - ▪ **ខេត្តស្វាយរៀង៖** សហការជាមួយអង្គការឆាលហ្វាន់កម្ពុជា រៀបចំឆ្លុះបញ្ចាំងអំពីវឌ្ឍនភាពនៃការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលាខេត្តស្វាយរៀង មានអ្នកចូលរួម ៧៦នាក់ ស្រី២៩នាក់។

## ១.២. ការជំនួបពិភាក្សាការងារ

- ខេត្តកណ្តាល៖ លោកជំទាវ អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ បានជំនួបពិភាក្សាការងារជាមួយតំណាងអង្គការដើម្បីកុមារ ក្រោមប្រធានបទការចូលរួមលើកកម្ពស់ចំណេះដឹង

និងអនុវត្តផែនការថ្នាក់ជាតិក្នុងកិច្ចការបង្ការ ការពារ និងឆ្លើយតប និងអំពើរំលោភបំពាន និងអំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារ នៅសាលាខេត្តកណ្ដាល។

**គ. ការងារសម្របសម្រួល**

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្ដីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ ១២១លើក មានអ្នកចូលរួមសរុប ១.៩៩៩នាក់(ស្រី ៩៥៩នាក់) ក្នុងនោះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ៣៣លើក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ០៧លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត ចំនួន ៨១លើក។ (ឧបសម្ព័ន្ធ១)

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឲ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្ដល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្ដល់អនុសាសន៍ ០៤ចំណុច និងវិធានការ ០៦ចំណុច របស់សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួងស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

### ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឲ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

**គ. សំណូមពរ**

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឲ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនីមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឲ្យលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ផ្តល់របាយការណ៍ឲ្យបានទៀងទាត់ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

**ឃ. សន្និដ្ឋាន**

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឲ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V. ទិសដៅត្រីមាសទី៤ ឆ្នាំ ២០២០

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឲ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាពជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឲ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៨. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឲ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឲ្យបានត្រឹមត្រូវ។

៩. បន្តរៀបចំវិធានការ "គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី" (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១០. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១១. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

១២. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃនៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្នមុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ......ខែ......ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៣ខែ......ឆ្នាំ២០២០

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ-ប៊ុនអេង**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**

- ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន
- សមាជិកក្រុមការងារគ.ជ.ប.ជ
- អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**"ដើម្បីជូនជ្រាប"**

- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

## តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ១២១លើក) មនុស្សចំនួន ១.៩៩៩នាក់ (ស្រី ៩៥៩នាក់)

| ស្ថាប័ន សម្របសម្រួល | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) | ▪ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួមជាអធិបតីភាព៖<br>- ក្នុងវេទិការកាផ្សព្វផ្សាយ ស្តីពីផលប៉ះពាល់ការធ្វើចំណាកស្រុកដោយប្រថុយប្រថាន និងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងបង្ការការឆ្លងការរីករាលដាលជំងឺកូវីដ១៩ និងប្រគល់ជូនអំណោយមួយចំនួន ទៅដល់បងប្អូនពលករ ប្រជាពលរដ្ឋដែលទើបវិលត្រលប់ពីក្រៅប្រទេស ចំនួន៣៨គ្រួសារ នៅភូមិល្បើក ឃុំខុនរ៉ង ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង។<br>- បើកសិក្ខាសាលាពិគ្រោះយោបល់លើកទី២ ស្តីពីការឆ្លើយតបទៅនឹងជនរងគ្រោះដែលកំពុងបន្លាស់ទី(ចំណាកស្រុក និងសមាហរណកម្ម) នៅសណ្ឋាគារភ្លាសស៊ី ខេត្តបាត់ដំបង។<br>- ពិធីសូត្រមន្ត បញ្ចុះបឋមសិលា កសាងមណ្ឌលទទួលពលករបញ្ជូនត្រលប់ និងជួបសំណេះសំណាលជាមួយរដ្ឋបាលស្រុកកំរៀង នៅឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង។<br>- ក្នុងកិច្ចប្រជុំពិនិត្យពិភាក្សាលើរបាយការណ៍វាយតម្លៃរបស់សហរដ្ឋអាមេរិក ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃ។<br>- សន្និសីទ ស្តីពីគំរូអនុវត្តល្អៗ ប្រឆាំងអំពើជួញដូរមនុស្ស និងគោលដៅឆ្ពោះទៅមុខ អបអរសាទរសមិទ្ធផលគម្រោងសំដៅនិរន្តភាពដែលរៀបចំឡើងដោយអង្គការវីនរ៉ក់កម្ពុជា នៅសណ្ឋាគារហ៊ីម៉ាវ៉ារី រាជធានីភ្នំពេញ។<br>- បានចុះត្រួតពិនិត្យការដ្ឋានសាងសង់មណ្ឌលទទួលពលករ នៅច្រកដូង ស្រុកកំរៀង និងបានបន្តដំណើរសួរសុខទុក្ខដល់កងកម្លាំងអធិការដ្ឋាននគរបាល ស្រុកកំរៀង ខេត្តបាត់ដំបង។<br>- បានអញ្ជើញចូលរួមដឹកនាំកិច្ចប្រជុំពិភាក្សា រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការបណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជា ស្តីពីការរៀបចំវគ្គបណ្តុះបណ្តាល ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធ និងជំនាញមូលដ្ឋាននៃការពិគ្រោះយោបល់តាមទូរស័ព្ទប្រកបដោយវិជ្ជាជីវៈ និងលើកកម្ពស់ការអន្តរាគមន៍ និងឆ្លើយតបប្រកបដោយមេត្រីលើអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការជួញដូរមនុស្ស នៅសាលប្រជុំ គ.ជ.ប.ជ។<br>- បានចុះសំណេះសំណាល និងចែកអំណោយជូនដល់ប្រជាពលរដ្ឋ និងពលករវិលត្រឡប់ពីប្រទេសថៃ ខេត្តបន្ទាយមានជ័យ។<br>    ○ នៅស្រុកមង្គលបូរី ចំនួន១០៣នាក់<br>    ○ នៅស្រុកព្រះនេត្រព្រះ ចំនួន១០០នាក់។ |

| | |
|---|---|
| | - អញ្ជើញជាអធិបតីក្នុងពិធីបើកសិក្ខាសាលា និងសម្របសម្រួល ក្នុងកិច្ចប្រជុំពិភាក្សាតុមូលក្នុងកម្មវិធី ដឹង គិត យល់ យោគយល់ នៅការិយាល័យមណ្ឌលព័ត៌មានស្ត្រីកម្ពុជា ក្រោមប្រធានបទ ស្តីពីចំណាកស្រុកដោយសុវត្ថិភាព និងស្វែងរកជំនួយពេលមានបញ្ហា នៅមណ្ឌលព័ត៌មានស្ត្រីកម្ពុជាក្រោមជំនួយភ្នាក់ងារសហប្រជាជាតិលើកកម្ពស់សមភាពយេនឌ័រ និង UN Woman។<br>- អញ្ជើញចូលរួមកិច្ចប្រជុំ ដើម្បីពង្រឹងកិច្ចសហការរវាងរដ្ឋាភិបាលសហរដ្ឋអាមេរិក និងរាជរដ្ឋាភិបាលកម្ពុជា ក្នុងការធ្វើឱ្យប្រសើរឡើងនូវសកម្មភាព និងលទ្ធផលនៃការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា ដែលដឹកនាំដោយលោកជំទាវ **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងជាប្រធានក្រុមការងារសហប្រតិបត្តិការអន្តរជាតិ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និង ឯកឧត្តម **W. Patrick Murphy** ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- បានចុះជួបសំណេះសំណាលជាមួយ ពលករទេសន្តរប្រវេសន៍ជាស្ត្រី ស្ត្រីមានផ្ទៃពោះ និងងាយរងគ្រោះ ក្នុងដំណាក់កាលនៃជំងឺកូវីដ១៩ របស់សហគមន៍ដែលជួបការលំបាក ដើម្បីទប់ស្កាត់ការជួញដូរមនុស្ស និងបានចែកជូនសំភារៈប្រើប្រាស់មួយចំនួនដល់ពលរដ្ឋ ចំនួន១០០គ្រួសារ ដែលឧបត្ថម្ភពីអង្គការ UNFPA និងអង្គការចាប់ដៃ នៅស្រុករមាសហែក ខេត្តស្វាយរៀង។<br>▪ លោកជំទាវវេជ្ជបណ្ឌិត ឧត្តមសេនីយ៍ឯក **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញចូលរួមៈ<br>- សិក្ខាសាលាពិគ្រោះយោបល់លើតារាងសកម្មភាព និងក្របខ័ណ្ឌត្រួតពិនិត្យ វាយតម្លៃ ផែនការយុទ្ធសាស្ត្រជាតិស្តីពី ពិការភាព ឆ្នាំ២០១០-២០២៣ មានអ្នកចូលរួមចំនួន២៨នាក់ ស្រី១២នាក់ នៅសណ្ឋាគារកាំបូឌីយ៉ាណា ភ្នំពេញ។<br>- វគ្គបណ្តុះបណ្តាលជំនាញ ស្តីពីការឆ្លើយតបអំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធ Internet រៀបចំដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងមានការឧបត្ថមសម្របសម្រួលដោយអង្គការ(Apple) នៅសណ្ឋាគារខេមរាអង្គរ ខេត្តសៀមរាប។<br>- កិច្ចប្រជុំជាន់ខ្ពស់ រវាងក្រសួងស្ថាប័នពាក់ព័ន្ធ នៃរាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិប្រចាំកម្ពុជា ស្តីពី "កម្មវិធីរួមគ្នាដើម្បីគាំទ្រជនអន្តោប្រវេសន៍ ដែលវិលត្រលប់ក្នុងស្ថានភាពវិបត្តិជំងឺកូវីដ-១៩ និងផលប៉ះពាល់" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគ.ជ.ប.ជ** នៅសាលប្រជុំក្រសួងមហាផ្ទៃ។<br>- កិច្ចប្រជុំក្រុមការងារបច្ចេកទេសអន្តរក្រសួង OCSE ដើម្បីពិនិត្យ និងផ្តល់យោបល់ លើសេចក្តីព្រាងផែនការសកម្មភាព ឆ្លើយតបលើអំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមប្រព័ន្ធ Internet រៀបចំដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងឧបត្ថមសម្របសម្រួលដោយអង្គការដែនដីមនុស្ស ហូឡង់ នៅសណ្ឋាគារអាស៊ាន ខេត្តកោះកុង។ |

- ផ្សព្វផ្សាយគោលនយោបាយជាតិស្តីពី "ប្រព័ន្ធកិច្ចការពារកុមារនៅកម្ពុជា" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម វង សូត្រ រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** នៅសាលប្រជុំទីស្តីការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។
- កិច្ចប្រជុំក្រុមការងារបច្ចេកទេសគណៈកម្មាធិការការពារកុមារថ្នាក់ជាតិ ដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រៀងផែនការ ការងារសម្រាប់អនុវត្តគោលនយោបាយជាតិ ស្តីពីប្រព័ន្ធកិច្ចការពារកុមារ អ្នកចូលរួមចំនួន៤៣នាក់ ស្រី១២នាក់។
- បានចុះធ្វើទស្សនកិច្ចអង្គការ អេ២១ និងបានជួបសំណេះសំណាលជាមួយលោកស្រីប្រធានអង្គការ អេ២១ ប្រចាំប្រទេសកម្ពុជា ពាក់ព័ន្ធទៅនឹងវិធីសម្ភាសន៍កុមារមេត្រី នៅខេត្តសៀមរាប។
- បានអញ្ជើញចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ លើសេចក្តីព្រាងផែនការសកម្មភាព ឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ិនធឺណែត នៅកម្ពុជា ក្រោមអធិបតីភាព លោកជំទាវ **ញ៉េប សុភាព** អគ្គលេខាធិការ នៃក្រុមប្រឹក្សាជាតិដើម្បីកុមារ នៅសណ្ឋាគារភ្នំពេញ។
- បានអញ្ជើញចូលរួមកិច្ចប្រជុំពិនិត្យរបាយការណ៍ ស្តីពីលទ្ធផលនៃការប្រជុំពិភាក្សាកម្រិតបច្ចេកទេស និងកម្រិតថ្នាក់ដឹកនាំ ផែនការថវិកាឆ្នាំ២០២១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី **រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** នៅទីស្តីការក្រសួងមហាផ្ទៃ។
-បានអញ្ជើញចូលរួមសិក្ខាសាលា ស្តីពីការលើកកម្ពស់កិច្ចការពារកុមារពីការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទ ក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ ក្រោមអធិបតីភាព លោកជំទាវ **ញ៉េប សុភាព** អគ្គលេខាធិការ នៃក្រុមប្រឹក្សាជាតិដើម្បីកុមារ នៅសណ្ឋាគារខេមរាអង្គរ ខេត្តសៀមរាប។
- បានអញ្ជើញចូលរួមវគ្គបណ្តុះបណ្តាលជំនាញពិគ្រោះយោបល់តាមទូរស័ព្ទ ដើម្បីឆ្លើយតបអំពើហឹង្សាលើស្ត្រី និងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាពលោកជំទាវ **សន សាបោន** អគ្គលេខាធិការរងនៃក្រុមប្រឹក្សាជាតិដើម្បីកុមារ និងលោក **ស៊ាន សុផៃ** នាយកប្រតិបត្តិអង្គការ Child Helpline Cambodia នៅភោជនីដ្ឋានទន្លេបាសាក់២។
- បានអញ្ជើញចូលរួមកិច្ចប្រជុំឆ្លុះបញ្ចាំងអំពីវឌ្ឍនភាព នៃការអនុវត្តការងារ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ ជ.ប.ជ. អ្នកចូលរួមចំនួន ៩០នាក់ នៅសាលាខេត្តស្វាយរៀង។

▪ **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**

- លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ៤០ច្បាប់ លិខិតចូល ២៨ច្បាប់។
- លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ៤២ច្បាប់ លិខិតចូល ៣៥ច្បាប់។
- រៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុ រាល់ពេលប្រជុំ។
- បូកសរុបរបាយការណ៍ប្រចាំសប្តាហ៍ ខែកក្កដា ខែសីហា ខែកញ្ញា ឆ្នាំ២០២០ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
- ប្រមូលរបាយការណ៍ពីអន្តរក្រសួង ស្ថាប័ន និងរាជធានី/ខេត្តទាំង២៥។
- រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមកិច្ចប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។

- ចងក្រងព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចូលក្នុងបណ្ណាសារវិគី។
- ស្រាវជ្រាវព័ត៌មានពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ពីមជ្ឈដ្ឋានផ្សេងៗ ជាពិសេសព័ត៌មានដែលចុះផ្សាយ នៅក្នុងបណ្តាញសង្គម និងគេហទំព័រនានា។
- Scan & Uploaded ឯកសារចូលក្នុងបណ្ណាសារនៃប្រព័ន្ធ wiki បានចំនួន ១៦០ច្បាប់។
- អាប់ឡូតរូបភាពសកម្មភាព គ.ខ.ប.ជ ចូលបណ្ណាល័យរូបភាពក្នុងប្រព័ន្ធអ៊ិនធើណេត wiki បានចំនួន ៨៧សកម្មភាព។

▪ **ក្រុមជំនួយកិច្ចការយុត្តិធម៌**

- ឯកឧត្តម អគ្គលេខាធិការរង និងជាអនុប្រធានគណៈកម្មការរៀបចំសទ្ធានុក្រមបច្ចេកសព្ទក្នុងវិស័យសន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈនៃក្រសួងមហាផ្ទៃ បានដឹកនាំសម្របសម្រួលកិច្ចប្រជុំពិភាក្សាក្នុងក្រុមអនុគណៈកម្មការប្រឆាំងការជួញដូរមនុស្ស ជាមួយគ្រូនគរបាលជាតិកម្រិតឧត្តមចំនួន០៤រូប និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចំនួន០៦រូប ដើម្បីរៀបចំសទ្ធានុក្រមបច្ចេកសព្ទជំនាញប្រឆាំងការជួញដូរមនុស្ស នាសប្តាហ៍ទីមួយ នៃខែកក្កដា បានចំនួន០៧សទ្ធានុក្រមបច្ចេកសព្ទ នៅសាលប្រជុំគ.ជ.ប.ជ។
- ឯកឧត្តម អគ្គលេខាធិការរង ទទួលបន្ទុកក្រុមជំនួយកិច្ចការយុត្តិធ៌ម បានអញ្ជើញចូលរួមដឹកនាំប្រជុំពិនិត្យ និងរៀបចំសទ្ធានុក្រមបច្ចេកទេសសព្ទជំនាញប្រឆាំងការជួញដូរមនុស្ស របស់អនុគណៈកម្មការប្រឆាំងការជួញដូរមនុស្ស បន្តជាលើកទី៣ បានចំនួន៧ សទ្ធានុក្រមបច្ចេកទេសសព្ទជំនាញ អ្នកចូលរួមចំនួន១២នាក់ ស្រី ០៤នាក់ នៅសាលប្រជុំ គ.ជ.ប.ជ។

▪ **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់៖**

- បានរៀបចំកិច្ចប្រជុំពិនិត្យនិងផ្តល់យោបល់ទៅលើខ្លឹមសារ សេចក្តីព្រាងសៀវភៅ "ការអប់រំនិងលំនាំនៃការបង្រៀន ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស" ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងលោកជំទាវ **សឿ សុជាតា** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា មានអ្នកចូលរួមចំនួន២២នាក់ ស្រី០៣នាក់។
- បន្តប្រជុំពិនិត្យនិងផ្តល់យោបល់ទៅលើខ្លឹមសារសេចក្តីព្រាងសៀវភៅ "ការអប់រំនិងលំនាំនៃការ បង្រៀន ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស" ចំនួន០៥លើក អ្នកចូលរួមសរុប ៦០នាក់ ស្រី ០១នាក់។

▪ **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ៖**

- ឯកឧត្តម អគ្គលេខាធិការរង ទទួលបន្ទុកក្រុមជំនួយកិច្ចការការពារជនរងគ្រោះបានអញ្ជើញចូលរួម៖
  - ពិធីផ្សព្វផ្សាយគោលនយោបាយជាតិស្តីពី ប្រព័ន្ធកិច្ចការពារកុមារ ក្រោមអធិបតីភាព ឯកឧត្តម វង សូត្រ រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅសាលប្រជុំ ក្រសួងសង្គមកិច្ច។

| | |
|---|---|
| | ○ សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិសេចក្តីព្រាងចុងក្រោយ នៃគោលការណ៍ ណែនាំស្តីពីយន្តការបញ្ជូនជនរងគ្រោះ ក្រោមអធិបតីភាព ឯកឧត្តម **ញឹក វណ្ណារ៉ា** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅសណ្ឋាគារសាន់វ៉េ រាជធានីភ្នំពេញ។<br>○ វគ្គបណ្តុះបណ្តាលជំនាញស្តីពី ការឆ្លើយតបអំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធ Internet រៀបចំឡើង ដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ សហាការជាមួយ អង្គការAPLE នៅសណ្ឋាគារខេមរាអង្គរ ខេត្តសៀមរាប។<br>○ សិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងផែនការសកម្មភាព ឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ិ Internet នៅកម្ពុជា ជាមួយកុមារ និងយុវវ័យ នៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ។<br>○ កិច្ចប្រជុំក្រុមការងារបច្ចេកទេសអន្តរក្រសួង OCSE ដើម្បីត្រួតពិនិត្យផ្តល់យោបល់លើកម្រងសំណួរ នៃការសិក្សាស្រាវជ្រាវជាសកល ស្តីពីការបញ្ឈប់គ្រោះថ្នាក់លើកការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ អ្នកចូលរួមចំនួន៣០នាក់ ស្រី០៩នាក់ នៅសាលប្រជុំភោជនីយដ្ឋានទន្លេបាសាក់២ រាជធានីភ្នំពេញ។<br>○ កិច្ចប្រជុំក្រុមការងារបច្ចេកទេស នៃគណៈកម្មាធិការការពារកុមារថ្នាក់ជាតិ ក្រោមអធិបតីភាព លោកជំទាវ ញ៉េប សុភាព អគ្គលេខាធិការ នសអគ្គលេខាធិការដ្ឋានក្រុមបប្រឹក្សាជាតិដើម្បីកុមារ(ក.ជ.ក) នៅភោជនីយដ្ឋានឆ្នេរថ្មី ខេត្តព្រះសីហនុ។<br>○ កិច្ចប្រជប្រជុំប្រចាំត្រីមាសទី៣ ឆ្នាំ២០២០ ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការ និងពិភាក្សាការងារអនុវត្តកន្លងមក និងទិសដៅបន្ត មានអ្នកចូលរួម **៥០**នាក់ នៅទីស្តីការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។<br>▪ **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ**<br>-លោកជំទាវ អគ្គលេខាធិការរង ទទួលបន្ទុកក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ បានអញ្ជើញចូលរួមកិច្ចប្រជុំបច្ចេកទេសពិនិត្យសេចក្តីព្រាងផែនការកម្មភាពជាតិ ស្តីពីការអភិវឌ្ឍយុវជនកម្ពុជាឆ្នាំ(២០១៩- ២០២០) នៅភោជនីយដ្ឋានទន្លេបាសាក់២ រាជធានីភ្នំពេញ។ |
| **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** | -បានរៀបចំកិច្ចប្រជុំប្រចាំត្រីមាសទី៣ ស្តីពីការអនុវត្តសកម្មភាពការងាររបស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ ជាមួយអង្គការដៃគូដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ និងរកបញ្ហាប្រឈម ចំនួន០៣លើក អ្នកចូលរួមចំនួន១០៣នាក់ ស្រី៤៧នាក់។<br>-បានរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេស ដើម្បីពិនិត្យ និងកែសម្រួលលើគោលការណ៍ណែនាំស្តីពី យន្តការបញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន០១លើក នៅទីស្តីការក្រសួង។<br>-បានចូលរួមសិក្ខាសាលាចំនួន៣លើក៖ ១.សិក្ខាសាលា ស្តីពីការរៀបចំផែនការការងារឆ្នាំ២០២១ សម្រាប់កម្មវិធីអាស៊ាន-អូស្រ្តាលី ដើម្បីប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា(ASEAN-ACT)។ ២.ស្តីពីកិច្ចការពារកុមារពីអំពើជួញដូរ ការរំលោភបំពានផ្សេងៗ និងការធ្វើទេសន្តរប្រវេសន៍។ ៣.ស្តីពីការមិនបង្កមហន្តរាយ (Do No Harm(DND) Guideline) នៃកម្មវិធីអាស៊ាន អូស្រ្តាលី ដើម្បីប្រឆាំងការជួញដូរមនុស្ស(ASEAN ACT)។<br>-ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ជំនាញពិគ្រោះយោបល់តាមទូរស័ព្ទដើម្បីឆ្លើយតបអំពើហិង្សាលើស្ត្រី និងអំពើជួញដូរមនុស្ស ចំនួន០១លើក នៅភោជនីយដ្ឋានទន្លេបាសាក់២។ |

| លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ៨១លើក អ្នកចូលរួមសរុបចំនួន ១.៨០៩នាក់ (ស្រី ៨៦៤នាក់) | |
|---|---|
| ខេត្តកណ្ដាល | - លោកជំទាវអភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ<br>○ បានដឹកនាំកិច្ចប្រជុំប្រចាំខែកក្កដា ខែសីហា ឆ្នាំ២០២០ ចំនួន០២លើក អ្នកចូលរួមចំនួន៧០នាក់ ស្រី៤៤នាក់។<br>○ បានចូលរួមពិធីផ្សព្វផ្សាយគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ ចំនួន០១លើក នៅក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា។<br>○ បានចូលរួមជាអធិបតីក្នុងកិច្ចប្រជុំពិគ្រោះយោបល់ ស្តីពីការរៀបចំផែនការរួម ស្តីពីកិច្ចការពារកុមារ ផ្តោតលើផែនការពង្រឹងការថែទាំកុមារ និងការសមាហរណកម្ម នៅសាលប្រជុំអាគារ(C) សាលាខេត្តកណ្ដាល។<br>- ក្រុមការងារក្រុង-ស្រុក បានប្រជុំប្រចាំខែ ចំនួន ២៦លើក អ្នកចូលរួមចំនួន៥៧៨នាក់ ស្រី៣២៨នាក់។<br>- ក្រុមការងារក្រុង-ស្រុក បានប្រជុំពង្រឹងសមត្ថភាពក្រុមការងារ ចំនួន១៧លើក អ្នកចូលរួមចំនួន៣១៦នាក់ ស្រី២០នាក់។ |
| ខេត្តស្វាយរៀង | - លេខាធិការដ្ឋាន បានប្រជុំពិភាក្សាពង្រឹងវិធានការទប់ស្កាត់ និងគ្រប់គ្រងពលករឆ្លងដែនខុសច្បាប់ទៅប្រទេសវៀតណាមនៅទីស្នាក់ការច្រកទ្វារព្រំដែនអន្តរជាតិបាវិត ច្រកព្រំដែនអន្តរជាតិព្រៃវល្លិ៍ និងច្រកទ្វេភាគីសំរោង ចំនួន០៣លើក អ្នកចូលរួមចំនួន៥៦នាក់ ស្រី២៧នាក់។<br>- សហការជាមួយអង្គការ ឆាលហ្វាន់កម្ពុជា រៀបចំឆ្លុះបញ្ចាំងអំពីវឌ្ឍនភាពនៃការអនុវត្ត ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកចូលរួមចំនួន៧៦នាក់ ស្រី ២៩នាក់។ |
| ខេត្តសៀមរាប | - គ.ខ.ប.ជ ខេត្ត បានរៀបចំកិច្ចប្រជុំប្រចាំខែកក្កដា ខែសីហា ឆ្នាំ២០២០ ចំនួន០២លើក អ្នកចូលរួមចំនួន១១៣នាក់ ស្រី៦៨នាក់។<br>- បានរៀបចំកិច្ចប្រជុំយុត្តិធម៌ព្រហ្មទណ្ឌ ស្តីពីការនាំចេញដោយមិនស្របច្បាប់ នីតិវិធីនៃការឃាត់ខ្លួន ឃុំខ្លួនអនីតិជន ចំនួន០១លើក អ្នកចូលរួមចំនួន៨៧នាក់ ស្រី២៦នាក់។<br>- បានចូលរួមទទួលពលករដែលត្រឡប់ពីប្រទេសថៃ នៅច្រកអន្តរជាតិប៉ោយប៉ែត ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ។<br>- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើកទី២ ស្តីពីការឆ្លើយតបទៅនឹងជនងាយរងគ្រោះដែលកំពុងបំលាស់ទី(ចំណាកស្រុកនិងសមហរណកម្ម) ចំនួន០១លើក នៅខេត្តបាត់ដំបង។<br>- បានចូលរួមចុះបឋមសិលាសាងសង់មណ្ឌលទទួលពលករកំរៀង ចំនួន០១លើក នៅស្រុកកំរៀង ខេត្តបាត់ដំបង។ |
| ខេត្តបាត់ដំបង | - បានប្រជុំប្រចាំឆមាសទី១ ចំនួន០១លើក អ្នកចូលរួមចំនួន៥៧នាក់។<br>- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពី វិធីឆ្លើយតបចំពោះប្រជាពលរដ្ឋងាយរងគ្រោះ(ធ្វើចំណាកស្រុក និងការធ្វើសមាហរណកម្ម) ក្រោមអធិបតីភាព លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ។<br>- បានចូលរួមចុះបឋមសិលាសាងសង់មណ្ឌលទទួលពលករកំរៀង ចំនួន០១លើក នៅស្រុកកំរៀង។ |

| | |
|---|---|
| | - បានចូលរួមសិក្ខាសាលាស្តីពីការរំលឹកឡើងវិញអំពីការថែទាំជំនួស អំពីសិទ្ធិកុមារ កិច្ចការពារកុមារ និងការចូលរួមរបស់កុមារក្នុងការការពាររបស់ពួកគេ ការជួញដូរមនុស្ស ទេសន្តរប្រវេសន៍ ចំនួន០១លើក អ្នកចូលរួមចំនួន៧៧នាក់ ស្រី២៨នាក់។<br>- បានរៀបចំកិច្ចប្រជុំ ស្តីពីវិធីឆ្លើយតបចំពោះប្រជាពលរដ្ឋងាយរងគ្រោះ (ការធ្វើចំណាកស្រុក និងការធ្វើសមាហរណកម្ម) និងពិធីបញ្ចុះបឋមសិលាសាងសង់មណ្ឌលទទួលពលករកំរៀង ក្រោមអធីបតីភាព លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ អ្នកចូលរួមចំនួន៦៣នាក់ ស្រី២៧នាក់ នៅសណ្ឋាគារក្លាស៊ីស ខេត្តបាត់ដំបង។<br>- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តៈ<br>○ បានចូលរួមផ្សព្វផ្សាយ និងបណ្តុះបណ្តាលពង្រឹងសមត្ថភាពគ្រូបង្គោល ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងការទប់ស្កាត់អំពើជួញដូរមនុស្ស ចំនួន០៣លើក។<br>○ បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីវិធីឆ្លើយតបចំពោះប្រជាពលរដ្ឋងាយរងគ្រោះ (ការធ្វើចំណាកស្រុក និងការធ្វើសមាហរណកម្ម) នៅសណ្ឋាគារក្លាស៊ី និងស្ប៉ា។<br>○ បានចូលរួមប្រជុំផ្សព្វផ្សាយរបាយការណ៍ ស្តីពីការចុះយុទ្ធនាការផ្សព្វផ្សាយទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ និងពិភាក្សាលើសេចក្តីព្រាងតារាងបញ្ជីផាកពិន័យក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ។ |
| ខេត្តប៉ៃលិន | - បានចូលរួមកិច្ចប្រជុំស្តីពីការឆ្លើយតបចំពោះប្រជាពលរដ្ឋងាយរងគ្រោះ(ការធ្វើចំណាកស្រុក និងការធ្វើសមាហរណកម្ម) និងបញ្ចុះបឋមសិលាសាងសង់មណ្ឌលទទួលពលករ កំរៀង ក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ នៅខេត្តបាត់ដំបង។ |
| ខេត្តកំពង់ចាម | - មន្ទីរការងារ និងបណ្តុះបណ្តាលខេត្ត សហការជាមួយអង្គការពលកម្មអន្តរជាតិ រៀបចំកិច្ចប្រជុំផ្សព្វផ្សាយ ស្តីពីលទ្ធផលនៃការស្រាវជ្រាវផលប៉ះពាល់លើពលករទេសន្តរប្រវេសន៍ ដោយជំងឺកូវីដ១៩ និងក្រមសីលធម៌ក្នុងការជ្រើសរើស ព្រមទាំងយន្តការដោះស្រាយបណ្តឹងរបស់ពលករ ចំនួន០១លើក អ្នកចូលរួមចំនួន៤៦នាក់ ស្រី២៣នាក់។ |
| ខេត្តព្រះសីហនុ | - ក្រុមការងារលេខាធិការដ្ឋាន បានប្រជុំប្រចាំឆមាសទី១ និងទិសដៅបន្ត និងបានផ្សព្វផ្សាយផែនការសកម្មភាពដល់ក្រុមការងារអន្តរជំនាញ អ្នកចូលរួមចំនួន៥២នាក់ ស្រី២៨នាក់។ |
| ខេត្តតាកែវ | - ក្រុមការងារលេខាធិការដ្ឋាន បានប្រជុំប្រចាំឆមាសទី១ និងទិសដៅបន្ត និងបានផ្សព្វផ្សាយផែនការសកម្មភាពដល់ក្រុមការងារអន្តរជំនាញ ចំនួន០១លើក អ្នកចូលរួមចំនួន៥២នាក់ ស្រី២៨នាក់។ |
| ខេត្តឧត្តរមានជ័យ | - បានរៀបចំកិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់លើកកិច្ចការស្ត្រី និងកុមារចំនួន០១លើក អ្នកចូលរួមចំនួន១៧នាក់ ស្រី១២នាក់។<br>- បានសហការជាមួយការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ចូលរួមប្រឹក្សាយោបល់ករណីរំលោភសេពសន្ថវៈលើអនីតិជន នៅកងរាជអាវុធហត្ថខេត្តឧត្តរមានជ័យ ចំនួន០១លើក អ្នកចូលរួមចំនួន០៧នាក់ ស្រី០៣នាក់។ |
| ខេត្តក្រចេះ | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការឆ្លើយតបនឹងបទល្មើសផ្លូវភេទលើកុមារតាមប្រព័ន្ធ Internet ដែលរៀបចំដោយអង្គការសកម្មភាពដើម្បីកុមារ នៅខេត្តកែប។ |